# បច្ចុប្បន្នភាពនៃការទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាពជនជាតិដើមភាគតិចនៅកម្ពុជាឆ្នាំ២០២៦

## ទិវាអន្តរជាតិជនជាតិដើមភាគតិចពិភពលោក

## ទិដ្ឋភាពទូទៅ



ជនជាតិដើមភាគតិចសរុបមានចំនួនប្រមាណ ១៧២.៩៨០ នាក់ ស្មើ ១,១១% នៃប្រជាជនកម្ពុជាសរុបដែលកំពុងរស់នៅក្នុងខេត្ត-ក្រុងចំនួន១៥ នៃបណ្ដាខេត្ត-ក្រុងរាជធានីចំនួន២៥ នៃព្រះរាជាណាចក្រកម្ពុជា។ តាមការប៉ាន់ប្រមាណគឺមានជនជាតិដើមភាគតិចចំនួន ៤៨៨ សហគមន៍ដែលកំពុងប្រកបមុខរបរចិញ្ចឹមជីវិតតាមបែបកសិកម្មប្រពៃណីរបស់ខ្លួន រួមទាំងការធ្វើ "កសិកម្មវិលជុំ"[១] ឬ "ចំការវិលជុំ"។ ជំនឿប្រពៃណី និងអត្តសញ្ញាណរបស់សហគមន៍ជនជាតិដើមភាគតិចកម្ពុជាមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយដីធ្លីនិងធនធានធម្មជាតិ។[២]

## ក្របខ័ណ្ឌច្បាប់ក្នុងការទទួលបានកម្មសិទ្ធិដីសមូហភាព



សិទ្ធិទទួលបានដីធ្លីរបស់ជនជាតិដើមភាគតិចត្រូវបានការពារដោយច្បាប់ជាតិ និងច្បាប់អន្តរជាតិ។ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា៣១ ទទួលស្គាល់សិទ្ធិទាំងនេះ ដោយផ្អែកលើកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ចនិងវប្បធម៌ ដែលធានាសិទ្ធិទទួលបានលំនៅឋានសមរម្យ។ សេចក្ដីប្រកាសរបស់អង្គការសហប្រជាជាតិស្ដីពីសិទ្ធិជនជាតិដើមភាគតិចក៏បាន ទទួលស្គាល់សិទ្ធិរបស់ពួកគេលើដីធ្លី ដែនដី និងធនធានដែលពួកគេកាន់កាប់និងប្រើប្រាស់តាមប្រពៃណី ហើយតម្រូវឱ្យរដ្ឋផ្ដល់ការទទួលស្គាល់ និងការពារតាមផ្លូវច្បាប់។ នៅកម្ពុជា ច្បាប់ភូមិបាលឆ្នាំ២០០១ និងអនុក្រឹត្យលេខ៨៣ ឆ្នាំ២០០៩ បានទទួលស្គាល់កម្មសិទ្ធិសមូហភាពរបស់ជនជាតិដើមភាគតិច ប៉ុន្តែក្នុងការអនុវត្តជាក់ស្ដែងនៅតែប្រឈមនឹងបញ្ហា និងមិនទាន់ទទួលបាននូវការការពារយ៉ាងពេញលេញនៅឡើយ។

## វឌ្ឍនភាពនៃការទទួលបានកម្មសិទ្ធិដីសមូហភាព

ទោះបីជាដំណើរការចុះបញ្ជីបានកែឱ្យមានលក្ខណៈងាយស្រួលជាងមុនកាលពីឆ្នាំ២០២០ ក៏ដោយ ក៏នីតិវិធីនៅតែមានដំណើរការយឺតយ៉ាវ ដោយសារមានភាពស្មុគស្មាញ បញ្ហាតម្លៃខ្ពស់ និងមានរយៈពេលវែង។[៣]

**0%** **ឆ្នាំ ២០២៥**

ការចុះបញ្ជីកម្មសិទ្ធិដីសមូហភាពដំបូងបានធ្វើឡើងក្នុងឆ្នាំ២០១១។ ក្នុងរយៈពេល ១៤ ឆ្នាំ រហូតដល់ឆ្នាំ២០២៥ គឺមានតែសហគមន៍ជនជាតិដើមចំនួន ៤៣ (៨,៨១%) ក្នុងចំណោម ៤៨៨ ប៉ុណ្ណោះដែលទទួលបានកម្មសិទ្ធិដីសមូហភាព។[៤]

មិនមានរបាយការណ៍ពីការកើនឡើងនៃការ ផ្ដល់កម្មសិទ្ធិដីសមូហភាពឡើយចាប់ពីខែកក្កដា ឆ្នាំ២០២៤ ដល់ ខែកក្កដា ឆ្នាំ២០២៥។[៥]

**១៦០%** **ឆ្នាំ ២០២៦**

ឆ្នាំដែលមានវឌ្ឍនភាព

យោងតាមទិន្នន័យនិងព័ត៌មានផ្លូវការរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ គិតត្រឹមខែមិថុនា ឆ្នាំ២០២៦ សហគមន៍ជនជាតិដើមភាគតិចដែលត្រូវបានចុះបញ្ជី និងទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាពមានចំនួន ៥៩ សហគមន៍[៦] ដែលស្មើនឹង ១២,០៩% ក្នុងចំណោម ៤៨៨ សហគមន៍ជនជាតិដើមភាគតិចនៅទូទាំងព្រះរាជាណាចក្រកម្ពុជា។ វឌ្ឍនភាពពី ៤៣ សហគមន៍គិតត្រឹមខែ មិថុនា ឆ្នាំ២០២៥ ដល់ ៥៩ សហគមន៍គិតត្រឹមខែ មិថុនា ឆ្នាំ២០២៦ គឺមានការកើនឡើងចំនួន ១៦ សហគមន៍ ដែលស្មើនឹង ១៦០% គឺបានបង្ហាញពីការប្ដេជ្ញាចិត្តនិងសម្រេចបានរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការចេញប័ណ្ណកម្មសិទ្ធិដីសមូហភាពចំនួន ១០ ក្នុងមួយឆ្នាំ។

ទិន្នន័យ និងព័ត៌មានដូចបានបង្ហាញនៅខាងលើគឺជា **សូចនាករវឌ្ឍនភាព** ដែលគួរឱ្យកត់សម្គាល់មួយរបស់រាជរដ្ឋាភិបាលដើម្បីពន្លឿនការចុះបញ្ជី និងផ្ដល់កម្មសិទ្ធិដីសមូហភាពជូនជនជាតិដើមភាគតិច!

### ទិន្នន័យ និងព័ត៌មានសង្ខេបអំពីសហគមន៍ជនជាតិដើមភាគតិចដែលត្រូវបានចុះបញ្ជី និងទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាព

៥៩ សហគមន៍ ត្រូវនឹង ១៩៧៤ ប័ណ្ណ លើទំហំផ្ទៃដី ៦២ ៤៩៥,៦៦៤០ ហិកតា ស្មើនឹង ៦៦៧៨ គ្រួសារ ក្នុងនោះ ៖

១. ខេត្តរតនគិរី មានចំនួន ៣៨ សហគមន៍ ត្រូវនឹង ១១៣០ ប័ណ្ណ លើទំហំផ្ទៃដី ៣៩ ៧១៥,១៧៤៩ ហិកតា ស្មើនឹង ៤១៥០ គ្រួសារ។

២. ខេត្តមណ្ឌលគិរី មានចំនួន ៨ សហគមន៍ ត្រូវនឹង ៤០១ ប័ណ្ណ លើទំហំផ្ទៃដី ៨ ៥៣១,៦៨ ហិកតា ស្មើនឹង ៥៧៨ គ្រួសារ។

៣. ខេត្តក្រចេះ មានចំនួន ៩ សហគមន៍ ត្រូវនឹង ៣៣១ ប័ណ្ណ លើទំហំផ្ទៃដី ៨ ២០៦,៣៩២៣ ហិកតា ស្មើនឹង ១៦២៥ គ្រួសារ។

៤. ខេត្តស្ទឹងត្រែង មានចំនួន ៤ សហគមន៍ ត្រូវនឹង ១១២ ប័ណ្ណ លើទំហំផ្ទៃដី ៦ ០៤២,៤១៦៨ ហិកតា ស្មើនឹង ៣៣៤ គ្រួសារ។

## បញ្ហាប្រឈម និងកង្វល់របស់ជនជាតិដើមភាគតិចនៅមូលដ្ឋាន

ទោះបីជាមានការកើនឡើងនៃចំនួនសហគមន៍ជនជាតិដើមភាគតិចដែលទទួលបានកម្មសិទ្ធិដីសមូហភាពពីចំនួន ៤៣ សហគមន៍គិតត្រឹមខែ មិថុនា ឆ្នាំ២០២៥ ដល់ ៥៩ សហគមន៍គិតត្រឹមខែ មិថុនា ឆ្នាំ២០២៦ ក៏ដោយ តែពួកគាត់នៅតែជួបបញ្ហាប្រឈម និងមានក្ដីកង្វល់ជាទូទៅមួយចំនួនដូចខាងក្រោម៖

- ដំណើរការយូរក្នុងការផ្ដល់កម្មសិទ្ធិដីសមូហភាពដល់ជនជាតិដើមភាគតិចនៅតែបន្តរារាំងដល់សិទ្ធិអាស្រ័យលើដីធ្លីតាមប្រពៃណី និងមានលំនៅដ្ឋានសមរម្យរបស់ពួកគេដែលត្រូវបានធានា និងការពារដោយច្បាប់ជាតិ និងច្បាប់អន្តរជាតិ។
- ដីរបស់សហគមន៍ជនជាតិដើមភាគតិចរួមមាន ដីចម្ការ វិលជុំ ដីកប់សព និងដីអារក្សជាដើម នៅតែរងផលប៉ះពាល់ដោយសារប្រតិបត្តិការរបស់ក្រុមហ៊ុនឯកជន។
- ជនជាតិដើមភាគតិចមានក្ដីបារម្ភយ៉ាងខ្លាំងចំពោះគម្រោងអភិវឌ្ឍន៍ថ្មីៗដែលនឹងត្រូវបានអនុម័តដោយរាជរដ្ឋាភិបាល។
- ការកាប់ទន្ទ្រានដីព្រៃ និងការរុករករ៉ែកំពុងយាយីដល់ ជីវភាពរស់នៅតាមបែបប្រពៃណីរបស់សហគមន៍ជនជាតិដើមភាគតិច។
- ការចេញប័ណ្ណកម្មសិទ្ធិឱ្យបុគ្គលឯកជនដែលមានឥទ្ធិពលជាន់ទៅលើដីសហគមន៍ជនជាតិដើមភាគតិចដែលទទួលបានប័ណ្ណកម្ម សិទ្ធិសមូហភាពហើយ កំពុងជាបញ្ហាយ៉ាងចាក់ស្រេះដោះស្រាយមិនចេញ។
- ជនជាតិដើមភាគតិចនៅតំបន់ព្រំប្រទល់កម្ពុជា-ថៃ មានក្ដីបារម្ភយ៉ាងខ្លាំងថាពួកគេនឹងក្លាយជាជនគ្មានដីធ្លី គ្មានផ្ទះសម្បែង និងគ្មានលទ្ធភាពអាស្រ័យផលលើធនធានធម្មជាតិ ដោយសារតែការរំលោភយកពីសំណាក់យោធាថៃ។[៧]

## អនុសាសន៍ចំពោះរាជរដ្ឋាភិបាល

- សូមរាជរដ្ឋាភិបាល និងក្រសួងមានសមត្ថកិច្ចបន្តពន្លឿនការចុះបញ្ជី និងផ្ដល់កម្មសិទ្ធិដីសមូហភាពដល់ សហគមន៍ជនជាតិដើមភាគតិចតាមការប្ដេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលឱ្យបាន ១០ សហគមន៍ក្នុងមួយឆ្នាំ។
- សូមរាជរដ្ឋាភិបាលចាត់វិធានការប្រកបដោយប្រសិទ្ធភាពដើម្បីការពារដីប្រពៃណីរបស់សហគមន៍ជនជាតិដើមភាគតិចពីការរំលោភបំពាន ឬផលប៉ះពាល់ដែលបង្កឡើងដោយសកម្មភាពរបស់ក្រុមហ៊ុនឯកជនស្របតាម ច្បាប់ជាតិ និងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ។
- សូមរាជរដ្ឋាភិបាលធានាថាគម្រោងអភិវឌ្ឍន៍ថ្មីៗទាំងអស់ដែលនឹងត្រូវបានផ្ដល់អាជ្ញាប័ណ្ណ នឹងមិនត្រូវប៉ះពាល់ដល់ដី និងធនធានប្រពៃណីរបស់សហគមន៍ជនជាតិដើមភាគតិច ដោយពង្រឹងការនុវត្តការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គមជាមុនប្រកបដោយតម្លាភាពនិងប្រសិទ្ធភាព។
- សូមរាជរដ្ឋាភិបាល និងអាជ្ញាធរមានសមត្ថកិច្ចចាត់វិធានច្បាប់យ៉ាងម៉ឺងម៉ាត់បំផុតចំពោះជនប្រព្រឹត្តបទល្មើសកាប់ទន្ទ្រានដីព្រៃ និងរុករករ៉ែខុសច្បាប់ ដោយអនុទ្យោមតាមច្បាប់ស្ដីពីព្រៃឈើ ច្បាប់ស្ដីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ និងក្រមបរិស្ថាន និងធនធានធម្មជាតិ។
- សូមរាជរដ្ឋាភិបាលនិងស្ថាប័នមានសមត្ថកិច្ចធានាថា នឹងមិនមានការចេញប័ណ្ណកម្មសិទ្ធិឯកជនជាន់លើដីកម្មសិទ្ធិសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិចតទៅទៀតឡើយ និងសូមដោះស្រាយករណីដែលបានកើតឡើងរួចហើយខាងលើដោយប្រគល់ដីដែលបាត់បង់មកឱ្យសហគមន៍វិញតាមទំហំដីដែលបានកំណត់នៅក្នុងប័ណ្ណកម្មសិទ្ធិដីសមូហភាព។
- សូមរាជរដ្ឋាភិបាលបង្កើតនីតិវិធីទាមទារការស្ដារឡើងវិញនិងសំណងសម្រាប់អ្នកដែលមានទ្រព្យសម្បត្តិ និងដីធ្លីរបស់ពួកគេត្រូវបានរងការខូចខាត បំផ្លាញ និងរឹបអូស ដោយសារជម្លោះព្រំដែន ជាពិសេសត្រូវយកចិត្តទុកដាក់និងធានាថាស្ត្រី សហគមន៍ជនជាតិដើមភាគតិច ជនមានពិការភាព និងក្រុមដែលងាយរងគ្រោះផ្សេងទៀតអាចទទួលបាននូវនីតិវិធីទាំងនេះយ៉ាងពេញលេញ៕

## ប្រភព


១. របាយការណ៍អំពីស្ថានភាពប្រជាសាស្ត្រ និងសង្គម-សេដ្ឋកិច្ចរបស់ជនជាតិដើមភាគតិចកម្ពុជា ឆ្នាំ២០២១ ទំព័រ ១២ ២៦ និង១៧០។
២. ម.ស.ម.ក «ទិវាជនជាតិដើមភាគតិចពិភពលោក» ខែសីហា ឆ្នាំ២០២៣។
៣. ម.ស.ម.ក «បច្ចុប្បន្នភាពនៃការទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាពជនជាតិដើមភាពតិចនៅកម្ពុជាឆ្នាំ២០២៥។
៤. ម.ស.ម.ក «បច្ចុប្បន្នភាពនៃការទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាពជនជាតិដើមភាពតិចនៅកម្ពុជាឆ្នាំ២០២៥។
៥. ម.ស.ម.ក «បច្ចុប្បន្នភាពនៃការទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាពជនជាតិដើមភាពតិចនៅកម្ពុជាឆ្នាំ២០២៥។
៦. លិខិតរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ លេខ ២១០២ ដនស/អសដក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៦ ឆ្លើយតបចំពោះលិខិតរបស់ ម.ស.ម.ក លេខ ០០២៥១/២៦/ម.ស.ម.ក ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២៦ ស្នើសុំទិន្នន័យបច្ចុប្បន្នភាពចំនួនបណ្ណកម្មសិទ្ធិដីសមូហភាពសគមន៍ជនជាតិដើមភាគតិចនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០២៦។
៧. ម.ស.ម.ក «គំណត់ត្រាសង្ខេប ៖ ការផ្លាស់ទីលំនៅក្នុងអំឡុងពេលមានជម្លោះព្រំដែនរវាងកម្ពុជានិងថៃ ខែធ្នូ ឆ្នាំ២០២៥»។


យើងសូមស្វាគមន៍ចំពោះព័ត៌មានដែលមានលក្ខណៈស្ថាបនា ធ្វើបច្ចុប្បន្នភាព និងព័ត៌មានសម្រាប់ការកែតម្រូវ!


មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights


ខែកក្កដា ឆ្នាំ២០២៦


CC BY NC SA